# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦ ស.ស.ម.

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសំរាប់កិច្ចប្រជុំលើកទី ៤ របស់អភិបាលខេត្ត ក្រុងជាប់ព្រំដែនកម្ពុជា វៀតណាម

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកត/១០៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ១៦៨០ សជណ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

### សំរេច

**ប្រការ១ :**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីសំរបសំរួលរៀបចំខ្លឹមសារសំរាប់កិច្ចប្រជុំអភិបាលខេត្ត ក្រុងជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី ៤ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ញ៉ឹ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | | អនុប្រធាន |
| ៣-ឯកឧត្តម សៀង ឡាប្រេស្ស | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤-តំណាងគណៈកម្មាធិការចំរុះកិច្ចការព្រំដែន | | សមាជិក |
| ៥-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |

www.pheakdeylaw.com

៦-តំណាងក្រសួងការពារជាតិ សមាជិក
៧- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
៨-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក
៩-តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
១០-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក
១១-តំណាងក្រសួងទេសចរណ៍ សមាជិក
១២-អគ្គនាយករដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១៣-តំណាងអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ២ :**

ក្រុមការងារនេះ មានភារកិច្ចពិភាក្សា និងសំរបសំរួលជាមួយក្រុមការងារវៀតណាម ដើម្បីរៀបចំខ្លឹមសារនានា សំរាប់កិច្ចប្រជុំ លើកទី ៤ រវាងខេត្ត ក្រុងជាប់ព្រំដែនកម្ពុជា វៀតណាម អោយដំណើរការបានលទ្ធផលល្អប្រសើរ ។

**ប្រការ៣ :**

- ក្នុងការអនុវត្តការងារ ប្រធានក្រុមការងារត្រូវសុំយោបល់ដឹកនាំផ្ទាល់ពី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អនុប្រធាន និង សមាជិកក្រុមការងារ ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារ ។

**ប្រការ៤ :**

ប្រធានក្រុមការងារ អាចស្នើសុំមន្ត្រីនៃទីស្តីការក្រសួងមហាផ្ទៃ និងមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងក្រុមការងារ និងក្រុមការងារដទៃទៀត អោយជួយការងារតាមការចាំបាច់ តាមការសំរេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬ ប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ ។

**ប្រការ៥ :**

ក្រុមការងារ បញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាលរួចរាល់ជាស្ថាពរ ។

**ប្រការ៦ :**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com